**ការនិយមវត្ថុប្រើប្រាស់៖** ការនេះទាក់ទិននឹងជំនឿដ៏ខ្លាំងក្លាក្នុងការទទួលបានឥវ៉ាន់សម្រាប់អ្នកប្រើប្រាស់ និងការមានជំនឿដែលថាកម្មសិទ្ធិនៃវត្ថុទាំងនេះ ជាការល្អប្រសើរបំផុត និងជាការមានតម្លៃខ្ពស់បំផុតនៅក្នុងការរស់នៅ។ ចំពោះមនុស្សវ័យក្មេង ការនិយមវត្ថុប្រើប្រាស់សង្កត់ធ្ងន់ទៅលើគំនិតបី។ ទីមួយ គឺគំនិតអំពីប្រាក់ និងកម្មសិទ្ធិវត្ថុ គឺជាសញ្ញាបញ្ជាក់ឲ្យដឹងអំពីជោគជ័យ ដូច្នេះហើយវត្ថុទាំងនេះផ្តល់ឲ្យគេនូវឋានៈ។ ទីពីរ គឺជំនឿដែលថាប្រាក់ និងកម្មសិទ្ធិវត្ថុ ផ្តល់ឲ្យគេនូវភាពស្កប់ចិត្ត។ ទីបី គឺថាការនិយមវត្ថុប្រើប្រាស់ គឺអំពីជម្រើសដែលផ្តល់ឲ្យបុគ្គលនីមួយៗ ដូច្នេះហើយបុគ្គលនោះមានជម្រើសទាំងឡាយដើម្បីអនុវត្ត។

**ការស្រឡាញ់ងប់នឹងខ្លួនឯង៖** នេះគឺជាកង្វល់ដ៏លើសលប់អំពីខ្លួនឯង។ ការនេះមានដំណើរការបីយ៉ាង គឺការយកចិត្តទុកដាក់ចំពោះផលប្រយោជន៍ខ្លួនឯង ដែលបង្ហាញពីចរិតលក្ខណៈដោយមានជំនឿថា ជីវិតរស់នៅគឺអំពីបុគ្គលផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ ទីពីរ មនុស្សវ័យក្មេងអាចស្វែងរកតម្លៃខ្លួនឯង ដោយបង្ហាញតម្លៃខ្លួនគេតាមរយៈការធ្វើឲ្យបានសម្រេច។ ទីបី គឺការស្រឡាញ់ខ្លួនឯងដែលជាក្តីកង្វល់យ៉ាងច្បាស់ អំពីការបង្ហាញរូបរាងខាងក្រៅរបស់ខ្លួនឯង។

**អត្ថិភាពនិយម៖** នេះគឺជាជំនឿដែលថា ជីវិតរស់នៅពុំមានអត្ថន័យជាប់មកជាមួយឡើយ ហើយក៏ពុំមានផែនការគ្របដណ្តប់លើសលប់សម្រាប់ធ្វើតាមដែរ។ ចំពោះមនុស្សវ័យក្មេង ការនេះមានដំណើរការបីយ៉ាង៖ ទីមួយគឺចេតនា ឬគោលបំណងដោយសារការគ្មានគោលបំណងក្នុងការរស់នៅ នោះគេក៏បង្កើតគោលបំណងខ្លួនឯង។ ទីពីរ គឺដោយសារការរស់នៅពុំមានគោលបំណង ឬអត្ថន័យគ្របដណ្តប់លើសលប់ ហេតុដូច្នេះគឺជាការល្អបំផុតដែលត្រូវរកវាឲ្យបាន នៅពេលអនាគតឆាប់ៗនេះ។ ទីបី គឺឯករាជ្យភាព ពេលដែលអត្ថន័យ និងគោលបំណងត្រូវបានស្វែងរកតាមរយៈការទាក់ទងគ្នាទៅវិញទៅមកជាមួយអ្នកដទៃ គេឃើញខ្លួនគេដូចជាពុំពឹងបានអ្វីពីនរណាម្នាក់ឡើយ ហើយក៏ពុំជំពាក់អ្វីចំពោះនរណាម្នាក់ដែរ។

- កូនសៀវភៅតូចនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ការយល់ដឹងជ្រៅជ្រះអំពីជំនឿរបស់មនុស្សវ័យក្មេង ដែលបញ្ចេញសកម្មភាពតាមឥរិយាបថរបស់គេ។ ពុំមែនមនុស្សវ័យក្មេងទាំងអស់អាចបង្ហាញឲ្យឃើញលក្ខណៈទាំងនេះឡើយ។
- ឥរិយាបថនេះពុំត្រូវឲ្យភ័យខ្លាចឡើយ វាគ្រាន់តែជារបៀបដែលមនុស្សវ័យក្មេងយល់ដឹងអំពីរឿងរ៉ាវទាំងឡាយតែប៉ុណ្ណោះ។
- ជួនកាលឥរិយាបថប្រព្រឹត្តបទល្មើសរបស់មនុស្សវ័យក្មេងគឺជាលទ្ធផលនៃបញ្ហាអប់រំកាលគេនៅក្មេង និងកត្តាសង្គមដទៃទៀតដូចជាគ្រឿងញៀន និងសុរាជាដើម។ ក្នុងករណីទាំងនេះ ជនទាំងនោះអាចត្រូវការជំនួយក៏ប៉ុន្តែពុំមែនការដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរឡើយ។
- មនុស្សវ័យក្មេងភាគច្រើនពុំមែននៅទីនោះដើម្បីបង្កគ្រោះថ្នាក់ដល់លោកអ្នកឡើយ។ ផ្ទុយទៅវិញ គេទាំងឡាយគ្រាន់តែចេញក្រៅដើម្បីមានពេលសប្បាយរីករាយ និងចំណាយពេលជាមួយមិត្តភក្តិរបស់គេប៉ុណ្ណោះ!

ព័ត៌មានក្នុងអត្ថបទនេះ
បានដកស្រង់ចេញពី:
www.youthtrain.com/assets/samples/p4/ p4_bk_3.pdf

An Australian Government Initiative
THE HEIGHTS COMMUNITY SERVICES
CONNECTING COMMUNITIES
Seniors Safety Strategy



# ការយល់ដឹងអំពីឥរិយាបថរបស់យុវវ័យ

# ការយល់ដឹងអំពីឥរិយាបថរបស់មនុស្សវ័យក្មេង

យុវវ័យ គឺជាអំឡុងពេលមួយដែលចង្អុលពីចរិតលក្ខណៈ តាមរយៈការផ្លាស់ប្តូរផ្នែកចិត្តសាស្រ្ត និងផ្នែករាងកាយ ពេលដែលមនុស្សវ័យក្មេងរីកចម្រើនពីកូនក្មេងក្នុងបន្ទុក ទៅជាមនុស្សពេញវ័យឯករាជ្យ។ អំឡុងពេលផ្លាស់ប្តូរនេះត្រូវបានធ្វើឲ្យរឹតតែស្មុគស្មាញ តាមរយៈការផ្លាស់ប្តូរផ្នែកសង្គម សេដ្ឋកិច្ច និងបច្ចេកវិទ្យាដែលបានកើតឡើងនៅប្រទេសអូស្រ្តាលី នៅទសវត្សរ៍ថ្មីៗនេះ។

ក្នុងដំណាក់កាលនៃការរស់នៅនេះ មនុស្សអាចងាយរងគ្រោះដោយសារឥទ្ធិពលនៃសម្ពាធក្រុមមនុស្សដូចគ្នានឹងវប្បធម៌ដែលគេនិយម ហើយអាចបន្ទន់ខ្លួនធ្វើពិសោធន៍ រុញច្រានព្រំដែន ហើយប្រថុយនឹងគ្រោះថ្នាក់ដែលអាចប៉ះទង្គិចលើសុខភាព និងសុខុមាលភាពរបស់គេនៅពេលភ្លាមៗ និងនៅពេលយូរអង្វែង។ លំនាំបែបបទ និងកម្រិតនៃឥរិយាបថខ្លះៗដែលនាំឲ្យប្រឈមមុខនឹងគ្រោះថ្នាក់ មានភាពខុសៗគ្នារវាងបុរសវ័យក្មេង និងស្រ្តីវ័យក្មេងដោយភាពទូទៅ ជាញឹកញាប់មានកម្រិតខ្ពស់ក្នុងចំណោមបុរសវ័យក្មេង។ ក្នុងភាពជាមនុស្សចាស់ជាង ជួនកាលលោកអ្នកអាចមានអារម្មណ៍ដូចជា លោកអ្នកកំពុងប្រាស្រ័យទាក់ទងជាមួយមនុស្សចម្លែកណាម្នាក់ ក្នុងខណៈដែលលោកអ្នកកំពុងនិយាយជាមួយមនុស្សវ័យក្មេង។ លោកអ្នកអាចយល់ថា របៀបដែលគេស្លៀកពាក់ និងសម្តែងឥរិយាបថ មានភាពខុសប្លែកពីបទពិសោធន៍របស់លោកអ្នក។



## ជំនឿរបស់យុវវ័យ

លោកអ្នកអាចសម្លឹងមើលរបៀបដែលគេធ្វើប្រតិកម្ម និងមានប្រតិកម្មទៅវិញទៅមក ហើយយល់ឃើញថា លោកអ្នកពុំយល់អ្វីអំពីគេឡើយ។ តទៅនេះគឺជាបញ្ជីនៃប្រព័ន្ធជំនឿមួយចំនួនរបស់មនុស្សវ័យក្មេង៖

តម្រេកនិយម៖ នេះគឺជាជំនឿដែលថាអត្ថន័យ និងសេចក្តីបំពេញចិត្តត្រូវបានរកឃើញតាមរយៈការស្វែងរកសេចក្តីរីករាយ និងការជៀសវាងនូវការឈឺចាប់។ មនុស្សដែលបានបង្ហាញឲ្យឃើញនូវឥរិយាបថតម្រេកនិយម ធ្វើតាមវិធានបីយ៉ាង។ ទីមួយ គឺការបំពេញចិត្តផ្ទាល់ខ្លួន ដែលតាមរយៈនេះ គេស្វែងរកសេចក្តីរីករាយសម្រាប់ខ្លួនគេ ក៏ប៉ុន្តែពុំមែនសម្រាប់អ្នកដទៃឡើយ។ ទីពីរ គឺការបំពេញចិត្ត តាមគំនិតខ្លួនឯង ដែលគេសម្រេចចិត្តថាតើមានអ្វីម្យ៉ាងនឹង ធ្វើឲ្យគេពេញចិត្តដោយផ្ទាល់ខ្លួន ឬអត់។ ទីបី គឺវិធាននៃការបំពេញចិត្តភ្លាមៗ ដែលគេរកមើលដើម្បីទទួលសេចក្តីរីករាយក្នុងរង្វង់ពេលអនាគតឆាប់ៗ។

ទំនាក់ទំនងនិយមៈ ការនេះបង្ហាត់ថាការពិត និងតម្លៃសីលធម៌ពុំមានដាច់ខាតឡើយ ក៏ប៉ុន្តែទាក់ទងជាមួយមនុស្ស ឬក្រុមដែលកាន់កាប់វា។ បើនិយាយម្យ៉ាងទៀតវិញគឺថា នៅពេលយើងប្រកាសថាអ្វីមួយវាត្រូវ ឬពិត នោះវាត្រូវ ឬពិតសម្រាប់យើងដោយផ្អែកទៅលើការអប់រំដែលទទួលកាលនៅក្មេង និងបទពិសោធន៍ក្នុងជីវិតរស់នៅរបស់យើងតែប៉ុណ្ណោះ។